# បើស្នេហ៍បែកបង...

បើស្នេហ៍បែកបងអូនរស់បែបណា    មានតែទុក្ខាតាមជាស្រមោល
គ្មានបងក្បែរអូនដូចក្បូនឥតថ្ពោល    រសាត់តែលតោលយោលលើផលសា។
ទំនុកនិងភ្លេងច្រៀងលេងរួមគ្នា    បីដូចសញ្ញាពឹងច័ន្ទឆាយា
គ្មានបងអូនដូចភមរីព្រាត់ផ្កា    មានត្រឹមអាត្មាសង្ខារឥតន័យ។
នៅលើលោកនេះមិនខ្វះទេមនុស្ស    មានស្រីមានប្រុសរស់ណែនផែនដី
តែបងជាមនុស្សខុសគេដទៃ    ចំពោះរូបស្រីថ្លៃឥតគេផ្ទឹម។
ក្នុងវង់ដៃបងនួនល្អងសុខសាន្ត    ខ្សែភ្នែកកល្យាណផ្ដល់ក្ដីសង្ឃឹម
ទោះមេឃអាប់អួមួហ្មងរលឹម    ពេលបងញញឹមចិត្តស្រីស្រស់ថ្លា។

ខ្ញុំដឹងធម៌ព្រះកើត-ចាស់-ឈឺ-ស្លាប់    តែសុំកុំឆាប់ឆក់យករៀមរ៉ា
ព្រះកាលអើយខ្ញុំសុំក្ដីមេត្តា    សូមលោកករុណាទុកពេលឱ្យខ្ញុំ។
បាននៅក្បែរបងសាសងអស់ចិត្ត    ក្រេបរសជីវិតស្ថិតក្នុងសុខុម
កេរ្ដិ៍ឈ្មោះយសសក្ដិមាសប្រាក់ទាំងដុំ    ខ្ញុំសុំលះបង្ករជាថ្នូរនឹងស្នេហ៍៕

ប៊ុនចាន់ ជ័យរាជ អភ័យសង្គ្រាម សុភ្រាសិរី